# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៣-១១-២០០៦-ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៤៦ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ ជូនមន្ត្រីជាន់ខ្ពស់ ២៤ រូប ជាទីប្រឹក្សា, ជំនួយការ និងអង្គរក្សផ្ទាល់ សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា ដែលមានស្នាដៃល្អ ក្នុងការបម្រើជាតិ មាតុភូមិ ៧៤៣៥

១៣-១១-២០០៦-ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៤៨ ស្តីពីការប្រោសព្រះរាជទានចំពោះ ឧកញ៉ា **ឡី គាត** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ៧៤៣៨


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


១៦-១១-២០០៦ -អនុក្រឹត្យលេខ ១២១ អនក្រ.បក ស្តីពីការកែសម្រួលរចនាសម្ព័ន្ធរបស់ស្នងការដ្ឋានពិសេសការពារបេតិកភណ្ឌ និងនគរបាលទេសចរណ៍ ឱ្យទៅជាការិយាល័យនគរបាលការពារបេតិកភណ្ឌ និងការិយាល័យនគរបាលទេសចរណ៍ ចំណុះស្នងការដ្ឋាននគរបាលខេត្តសៀមរាប ៧៤៣៩

១៧-១១-២០០៦ -អនុក្រឹត្យលេខ ១២២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧៤៤៥

១៧-១១-២០០៦ -អនុក្រឹត្យលេខ ១២៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧៤៤៧

១៦-១១-២០០៦ -អនុក្រឹត្យលេខ ៧១៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៤៤៩

១៦-១១-២០០៦ -អនុក្រឹត្យលេខ ៧១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤៥០

១៦-១១-២០០៦ -អនុក្រឹត្យលេខ ៧១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤៥១

១៧-១១-២០០៦ -អនុក្រឹត្យលេខ ៧១៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៧៤៥២

១៧-១១-២០០៦ -អនុក្រឹត្យលេខ ៧១៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៧៤៥៣


### ២-សេចក្តីសម្រេច


១៦-១១-២០០៦ -សេចក្តីសម្រេចលេខ ៤៩ សសរ ស្តីពីការទទួលដីប្រមាណ ២០ ហិកតា នៅភូមិស្រះកែវ ស្រុកសង្កែ ខេត្តបាត់ដំបង សំរាប់ធ្វើជាកន្លែងពិសោធន៍កសិកម្ម ៧៤៥៤


### ៣-បទបញ្ជា


១៥-១១-២០០៦ -បទបញ្ជាលេខ ០៤ បប ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ៧៤៥៦

## III-ការិយាល័យបណ្តាក្រសួង

### ១-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៣-១១-២០០៦ -ប្រកាសលេខ ១១០៩ សហវ.ប្រក ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារគោលនយោបាយស្តីពីការគ្រប់គ្រងផ្ទៃក្នុង ៧៤៦១


### ២-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


២៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេទើហ្វ័រឈ្មួន រៀល អ៊ីស្ទេត** ៧៤៧០

២៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡុង ស៊ី អ៊ិនដាសស្ទ្រៀល ខមមើសល អ៊ិនវេសមេន** ៧៤៧២

២៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ អិន ថ៉ាយ អ៊ីមផត អិចផត** ៧៤៧៤

២៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៤៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខាសល អន្តរពេជ្រ** ៧៤៧៦

២៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី ជី អាយ ធី គ្រុប** ៧៤៧៨

២៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៤៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ ស្តារ ហ្វូលឌីង ខូ អិលធីឌី** ៧៤៨០

២៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៤៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វីស្តាខាដ ខេមបូឌាន ត្រេឌីង ផ្ទូស** ៧៤៨២

២៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៥០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊្វូ ហាយ អ៊ិនធើណេសិនណាល ខូ អិលធីឌី** ៧៤៨៤

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផេស៊ីហ្វិក លីង (អូស្ត្រីសីស) ខនស្ត្រាក់សិន ជេខរ** ៧៤៨៦

២៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សន ហៃ អ៊ីមផត អិចផត** ៧៤៨៨

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៤៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៣ នាថ្ងៃទី២១ ខែមិនា ឆ្នាំ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ ជូនមន្ត្រីជាន់ខ្ពស់ ២៤ រូប ជាទីប្រឹក្សា, ជំនួយការ និងអង្គរក្សផ្ទាល់ **សម្តេច ហេង សំរិន** ប្រធានរដ្ឋសភា ដែលមានស្នាដៃល្អ ក្នុងការបម្រើជាតិ មាតុភូមិ ដូចរាយនាមខាងក្រោមនេះ:

**ក_ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេនា**

១- ឯកឧត្តម **ខង សូត** ជាទីប្រឹក្សាផ្ទាល់សម្តេច ទទួលបន្ទុកជាប្រធានក្រុមទីប្រឹក្សា

២- ឯកឧត្តម **មុំ ខេង** ជាទីប្រឹក្សាផ្ទាល់ និងជានាយកខុទ្ទកាល័យ សម្តេចប្រធានរដ្ឋសភា

៣- ឯកឧត្តម **គាំម កុសល** ជាទីប្រឹក្សាផ្ទាល់ និងជានាយករងខុទ្ទកាល័យ សម្តេចប្រធានរដ្ឋសភា

៤- ឯកឧត្តម **ចាយ បូរិន** ជាទីប្រឹក្សាផ្ទាល់ សម្តេចប្រធានរដ្ឋសភា

**ខ-ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ**

១- ឯកឧត្តម ម៉ៅ ញ៉ា ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ សម្តេចប្រធានរដ្ឋសភា

២- ឯកឧត្តម ប៊ុត គីមស៊ាន ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

៣- ឯកឧត្តម ឆា ចន្ទ័លីដា ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

៤- ឯកឧត្តម លៀង ផន ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

៥- លោកជំទាវ ឡុង សាខន ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

**គ-ព្រះរាជាណាចក្រកម្ពុជា ថ្នាក់សេនា**

១- ឯកឧត្តម ចាន់ យឿន ជាទីប្រឹក្សាផ្ទាល់ និងជានាយករងខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា

២- ឯកឧត្តម គុំ សារ៉ុន ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

៣- ឯកឧត្តម ឆឹម ស៊ីផា ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

៤- ឯកឧត្តម ផន ផែង ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

៥- ឯកឧត្តម ហាម សុទ្ធិ ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

៦- ឯកឧត្តម ម៉ៃ ឧុទ្ធី ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

**ឃ-ព្រះរាជាណាចក្រកម្ពុជា ថ្នាក់អស្សឫទ្ធិ**

១- ឯកឧត្តម កែវ ធី ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

២- ឯកឧត្តម ឡុញ វណ្ណៈ ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

៣- ឯកឧត្តម នូ នឹម ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

៤- ឯកឧត្តម អ៊ុំ វណ្ណា ជាទីប្រឹក្សា សម្តេចប្រធានរដ្ឋសភា

៥- លោក លី ឡេង ជំនួយការផ្ទាល់ទទួលបន្ទុកការងារមូលដ្ឋាន

៦- លោក ហ៊ុង រស្មី ប្រធានអង្គរក្សសម្តេចប្រធានរដ្ឋសភា

៧- លោក គាំ សុខាន់ អនុប្រធានអង្គរក្សសម្តេចប្រធានរដ្ឋសភា

៨- លោក ភាន់ ផា អង្គរក្សផ្ទាល់របស់ សម្តេចប្រធានរដ្ឋសភា

៩- លោក មាស ឈុនឡេង អង្គរក្សផ្ទាល់របស់ សម្តេចប្រធានរដ្ឋសភា

មាត្រា២: ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបាន សម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤៧.០៦១១.៤៧២

ធ្វើនៅព្រះបរមរាជវាំង ភ្នំពេញ, ថ្ងៃទី១៧ខែវិច្ឆិកា ឆ្នាំ២០០៦

លេខ : ៤៧៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា **ឆ្វី គាព**

នូវ

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.០៦១១.៤៧៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦

លេខ : ៤២៥ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យ៉ុង ជិនភេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលរចនាសម្ព័ន្ធរបស់ស្នងការដ្ឋានពិសេសការពារបេតិកភណ្ឌ និងនគរបាលទេសចរណ៍ ឱ្យទៅជាការិយាល័យនគរបាលការពារបេតិកភណ្ឌ និង ការិយាល័យនគរបាលទេសចរណ៍ ចំណុះស្នងការដ្ឋាននគរបាលខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២

ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួល មាត្រា ៦ និងមាត្រា ១៤ នៃអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ ១២៥ អនក្រ.បក ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការបង្កើតនាយកដ្ឋាននគរបាលទេសចរណ៍ នៃក្រសួងមហាផ្ទៃ
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**មាត្រា១ .-**

ត្រូវបាននិរាករណ៍អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតស្នងការដ្ឋានពិសេសការពារបេតិកភណ្ឌ ។

**មាត្រា២ .-**

ស្នងការដ្ឋានពិសេសការពារបេតិកភណ្ឌ ត្រូវបានកែសម្រួលទៅជាការិយាល័យនគរបាលការពារបេតិកភណ្ឌ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំរបស់ស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

**មាត្រា៣ .-**

ការិយាល័យនគរបាលការពារបេតិកភណ្ឌ ចំណុះស្នងការដ្ឋាននគរបាលខេត្តសៀមរាបមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

- លើកគម្រោងផែនការ និងអនុវត្តវិធានការមុខជំនាញតាមគោលការណ៍ដឹកនាំរបស់ស្នងការនគរបាលខេត្តសៀមរាប និងអភិបាលខេត្តសៀមរាប ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរអប្សរា
- សហការជាមួយកម្លាំងមានសមត្ថកិច្ច និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្នុងកិច្ចការពារសុវត្ថិភាព សន្តិសុខ និងរក្សារបៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ក្នុងភូមិសាស្ត្រតំបន់រមណីយដ្ឋានអង្គរ និងតំបន់ផ្សេងទៀតដែលកំណត់ដោយអាជ្ញាធរអប្សរា
- ស្រាវជ្រាវ និងអនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបរាល់អំពើល្មើសច្បាប់ ការបំផ្លិចបំផ្លាញ ការលួចលាក់ ប្លន់ ការទិញ លក់ និងការដឹកជញ្ជូនបេតិកភណ្ឌសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ ក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន

-សហការជាមួយនគរបាលទេសចរណ៍ ក្នុងកិច្ចការពារសុវត្ថិភាព សន្តិសុខភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ ដែលមកបំពេញបេសកកម្ម ធ្វើទស្សនកិច្ច ឬធ្វើទេសចរណ៍ក្នុងតំបន់រមណីយដ្ឋានអង្គរ សៀមរាប និងតំបន់ផ្សេងទៀត ដែលកំណត់ដោយអាជ្ញាធរអប្សរា

-ស៊ើបអង្កេតបទឧក្រិដ្ឋ ចាប់ខ្លួន ឃាត់ខ្លួន និងត្រួតពិនិត្យ ឆែកឆេរជនល្មើសដែលពាក់ព័ន្ធក្នុងការបំផ្លិចបំផ្លាញ ការលួចលាក់ ប្លន់ ការទិញ លក់ និងការដឹកជញ្ជូនបេតិកភណ្ឌសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រនៃតំបន់រមណីយដ្ឋានអង្គរ សៀមរាប កសាងសំណុំរឿង និងបញ្ជូនជនល្មើសជាមួយវត្ថុតាងទៅតុលាការ

-បោះទីតាំងឈរជើងការពារ និងចល័តយាមល្បាត ឃ្លាំមើលតាមចំណុចសំខាន់ៗនៃតំបន់រមណីយដ្ឋានអង្គរ សៀមរាប និងតំបន់ផ្សេងទៀត

-សហការជាមួយការិយាល័យនគរបាលទេសចរណ៍ នៃស្នងការដ្ឋានខេត្តសៀមរាប មេបញ្ជាការយោធភូមិភាគទី៤ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តសៀមរាប មេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប អភិរក្សដ្ឋាន អង្គរ មន្ទីរធម្មការ និងសាសនាខេត្ត មន្ទីរទេសចរណ៍ខេត្ត អង្គភាពគយ និងរដ្ឋាករប្រចាំខេត្ត និងអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត ដើម្បីអនុវត្តវិធានការបង្ការទប់ស្កាត់ បង្ក្រាប បទល្មើស និងការបង្គ្រោះមហន្តរាយបំផ្លិចបំផ្លាញដល់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រនៅក្នុងភូមិសាស្ត្រខេត្តសៀមរាប និងតំបន់ផ្សេងទៀតដែលកំណត់ដោយអាជ្ញាធរអប្សរា

-ធ្វើទំនាក់ទំនងជាមួយអង្គការ យូណេស្កូ និងអង្គការអន្តរជាតិនានា ដើម្បីទទួលការណែនាំ ផ្សព្វផ្សាយគោលការណ៍ផ្សេងៗ និងទទួលជំនួយឧបត្ថម្ភបម្រើឱ្យការងារការពារបេតិកភណ្ឌវប្បធម៌ តាមរយៈស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងអាជ្ញាធរអប្សរា

-ធ្វើសេចក្តីរាយការណ៍ជាប្រចាំ ឬជាបន្ទាន់អំពីសភាពការណ៍ និងហេតុការណ៍ផ្សេងៗ ដែលពាក់ព័ន្ធដល់ការអនុវត្តភារកិច្ច ក្នុងសមត្ថកិច្ចជំនាញរបស់ខ្លួន មកស្នងការនគរបាលខេត្តសៀមរាប អភិបាលខេត្តសៀមរាប និងអាជ្ញាធរអប្សរា

-ធ្វើបញ្ជីគ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យ របស់ការិយាល័យនគរបាលការពារបេតិកភណ្ឌតាមការកំណត់របស់ស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងស្របតាមការកំណត់របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ធ្វើការងាររដ្ឋបាល បុគ្គលិក ភស្តុភារ គណនេយ្យ និងថវិកា តាមការកំណត់របស់ស្នងការដ្ឋាននគរបាលខេត្តសៀមរាប

-សហការជាប្រចាំ ជាមួយអាជ្ញាធរអប្សរា ដើម្បីទទួលបាននូវបញ្ជីសារពើភណ្ឌ បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ នៅតំបន់រមណីយដ្ឋានអង្គរ សៀមរាប និងតំបន់ផ្សេងទៀតដែលអាជ្ញាធរអប្សរាគ្រប់គ្រង

-រៀបចំសំណើសុំគោលការណ៍ជូនស្នងការដ្ឋាននគរបាលខេត្តសៀមរាប និង/ឬអាជ្ញាធរអប្សរា ដើម្បីចេញបទបញ្ជា និងចាត់វិធានការបង្ការ ទប់ស្កាត់បទល្មើស បង្គ្រោះថ្នាក់មហន្តរាយបំផ្លិចបំផ្លាញ ព្រមទាំងសុំឱ្យមន្ទីរនានាជុំវិញខេត្ត ផ្តល់របាយការណ៍ព័ត៌មាន និងឯកសារពាក់ព័ន្ធដល់ការការពារបេតិកភណ្ឌសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ នៅតំបន់រមណីយដ្ឋានអង្គរ សៀមរាប និងតំបន់ផ្សេងទៀតដែលកំណត់ដោយអាជ្ញាធរអប្សរា

-គ្រប់គ្រងដឹកនាំ បញ្ជាកងកម្លាំងនគរបាលជាតិ ចំណុះការិយាល័យនគរបាលការពារបេតិកភណ្ឌ ដើម្បីធានាដល់ការអនុវត្តគោលការណ៍ បទបញ្ជារបស់ស្នងការនគរបាលខេត្តសៀមរាប អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ និង រាជរដ្ឋាភិបាលកម្ពុជា

-អនុញ្ញាតច្បាប់ឈប់សំរាក ដាក់ពិន្ទុ និងមូលវិចារណ៍ ស្នើសរសើរ ស្នើតែងតាំងមុខតំណែង បំពាក់ឋានន្តរស័ក្តិ ផ្ទេរភារកិច្ច ដាក់វិន័យ ដកហូតមុខតំណែង និងឋានន្តរស័ក្តិនាយនគរបាល នាយនគរបាលរង និងពលនគរបាលចំណុះការិយាល័យនគរបាលការពារបេតិកភណ្ឌ តាមការកំណត់របស់ស្នងការដ្ឋាននគរបាលខេត្តសៀមរាប

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលស្នងការនគរបាលខេត្តសៀមរាប អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប អគ្គស្នងការនគរបាលជាតិ និងក្រសួងមហាផ្ទៃ ប្រគល់ឱ្យ ។

**មាត្រា៤ .-**

ត្រូវបានផ្ទេរអង្គភាពនគរបាលទេសចរណ៍ ដែលបច្ចុប្បន្នកំពុងបំពេញភារកិច្ចនៅក្រោមការគ្រប់គ្រង និងដឹកនាំរបស់នាយកដ្ឋាននគរបាលទេសចរណ៍ នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ ឱ្យទៅជាការិយាល័យនគរបាលទេសចរណ៍ ចំណុះស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

**មាត្រា៥ .-**

ការិយាល័យនគរបាលទេសចរណ៍ចំណុះស្នងការដ្ឋាននគរបាលខេត្តសៀមរាប មានតួនាទី និងភារកិច្ច ដូចតទៅ :

-ធ្វើទំនាក់ទំនងជាមួយស្ថានទូត ស្ថានតំណាង និងអង្គការអន្តរជាតិនានា ដើម្បីផ្តល់ និងទទួលព័ត៌មានជុំវិញហេតុការណ៍ដែលពាក់ព័ន្ធដល់ភ្ញៀវទេសចរ ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្នងការដ្ឋាននគរបាលខេត្តសៀមរាប និង/ឬអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដើម្បីចំណាត់ការឱ្យបានសមស្រប និងទាន់ពេលវេលាទៅតាមការកំណត់របស់ច្បាប់ នៅក្នុងដែនដីខេត្តសៀមរាប

-ករណីមានបទល្មើសជាក់ស្តែងក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន មន្ត្រីនគរបាលទេសចរណ៍ត្រូវធ្វើអន្តរាគមន៍ចំពោះបទល្មើសនោះទៅតាមនីតិវិធីជាធរមាន

-សហការជាមួយកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីទប់ស្កាត់ ប្រឆាំងការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ពិសេស ស្ត្រី និងកុមារ និងដើម្បីបង្ការការពារឧប្បត្តិហេតុគ្រោះថ្នាក់ផ្សេងៗដែលអាចកើតឡើងជាយថាហេតុ ចំពោះភ្ញៀវទេសចរ

-សហការជាមួយសមត្ថកិច្ច និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ពាក់ព័ន្ធ ដើម្បីអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងអំពីនយោបាយទេសចរណ៍ជាតិ និងចេះស្វាគមន៍រួសរាយ រាក់ទាក់ ភ្ញៀវទេសចរ និងដើម្បីចូលរួមការពារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ នៅតំបន់រមណីយដ្ឋានអង្គរ សៀមរាប និងតំបន់ផ្សេងទៀត ដែលកំណត់ដោយស្នងការដ្ឋាននគរបាលខេត្តសៀមរាប អភិបាលខេត្តសៀមរាប និងអាជ្ញាធរអប្សរា

-សហការជាមួយមន្ទីរទេសចរណ៍ខេត្តសៀមរាប អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្រុក ឃុំក្នុងខេត្តសៀមរាប ដើម្បីទទួលព័ត៌មានពីភ្ញៀវទេសចរដែលចូលមកធ្វើទស្សនកិច្ច ទេសចរណ៍ក្នុងតំបន់ភូមិសាស្ត្រខេត្តសៀមរាប

-សហការជាមួយមន្ទីរពាក់ព័ន្ធក្នុងខេត្តសៀមរាប ដើម្បីចាត់តាំងបណ្តាញយុវជនស្ម័គ្រចិត្ត ឱ្យចូលរួមធ្វើជាអ្នកជំនួយការដល់ការការពារសន្តិសុខ សុវត្ថិភាព ជូនភ្ញៀវនៅតំបន់ទេសចរណ៍សំខាន់ៗនៅក្នុងខេត្តសៀមរាប

-លើកទិសដៅផែនការដឹកនាំបញ្ជាជំនាញនគរបាលទេសចរណ៍អនុវត្តភារកិច្ចថែរក្សាការពារសន្តិសុខ សុវត្ថិភាព និងផ្តល់ព័ត៌មានអំពីគោលដៅទេសចរណ៍ជូនភ្ញៀវទេសចរ តាមការកំណត់នៃច្បាប់

-អនុវត្តវិធានការមុខជំនាញ តាមគោលការណ៍ដឹកនាំរបស់ស្នងការនគរបាលខេត្តសៀមរាប អភិបាលខេត្តសៀមរាប និងអាជ្ញាធរអប្សរា

-ចាត់វិធានការចាំបាច់នានា បង្ការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលារាល់សកម្មភាពផ្សេងៗ ដែលបង្កឱ្យប៉ះពាល់ដល់រូបរាងកាយ អាយុជីវិត ទ្រព្យសម្បត្តិ និងកិត្តិយសរបស់អ្នកទេសចរ ដោយគោរពឱ្យបាននូវសិទ្ធិមនុស្សជាមូលដ្ឋាន

-ផ្តល់ព័ត៌មានពិត និងឥតលាក់លៀមជូនភ្ញៀវទេសចរ

-បោះទីតាំងប្រចាំការ ការពារ និងល្បាតចល័តតាមចំណុចដែលមានការប្រមូលផ្តុំភ្ញៀវទេសចរ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការផ្តល់ ទទួលព័ត៌មាន និងអន្តរាគមន៍ទាន់ពេលវេលា សំដៅធានាសុវត្ថិភាពដល់ភ្ញៀវទេសចរ

-ជួយសម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរលើនីតិវិធី និងបែបបទរដ្ឋបាល បង្កលក្ខណៈងាយស្រួល និងភាពកក់ក្តៅជឿទុកចិត្តដល់ភ្ញៀវទេសចរក្នុងអំឡុងពេលស្នាក់នៅក្នុងខេត្តសៀមរាប ជៀសវាងនូវកិច្ចប្រតិបត្តិការផ្ទុយពីច្បាប់ និងលិខិតបទដ្ឋានបានកំណត់ និងរើសអើងជាតិសាសន៍

-ធ្វើសេចក្តីរាយការណ៍ជាប្រចាំតាមការកំណត់ ឬជាបន្ទាន់អំពីសភាពការណ៍ និងហេតុការណ៍ផ្សេងៗ ដែលពាក់ព័ន្ធដល់ការអនុវត្តភារកិច្ចរបស់ខ្លួនមកស្នងការនគរបាលខេត្តសៀមរាប អភិបាលខេត្តសៀមរាប និងអាជ្ញាធរអប្សរា

-ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់នគរបាលជាតិ កសាងស្នាដៃ និងកិត្តិយសរបស់នគរបាលទេសចរណ៍

-ធ្វើការងារបុគ្គលិក រដ្ឋបាល ភស្តុភារ និងគណនេយ្យរបស់អង្គភាពខ្លួនតាមការកំណត់របស់ស្នងការនគរបាលខេត្តសៀមរាប

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលស្នងការនគរបាលខេត្តសៀមរាប អភិបាលខេត្តសៀមរាប អាជ្ញាធរអប្សរា អគ្គស្នងការនគរបាលជាតិ និងក្រសួងមហាផ្ទៃ ប្រគល់ឱ្យ ។

**មាត្រា៦ .-**

ការិយាល័យនគរបាលការពារបេតិកភណ្ឌ និងការិយាល័យនគរបាលទេសចរណ៍ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរអប្សរា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៨
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១.៧២១ លានរៀល ( មួយពាន់ប្រាំពីររយម្ភៃមួយលានរៀលគត់ ) ពី ជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) ជូនក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយទូទៅរបស់ស្ថានទូត ស្ថានកុងស៊ុល ថ្លៃឈ្នួលស្ថានទូត និង ផ្ទះមន្ត្រីការទូត និង ចំណាយចូលរួមប្រជុំនិងបេសកកម្មនានា សំរាប់ឆ្នាំ ២០០៦។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ ✓

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៣.៩៦៥ លានរៀល (បីពាន់ប្រាំបួនរយហុកសិបប្រាំលានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនអាជ្ញាធរអប្សរា សំរាប់ចំណាយរៀបចំប្រព័ន្ធអគ្គិសនីនៅក្បែរមជ្ឈមណ្ឌលពិព័រណ៍វប្បធម៌ពិភពលោកអង្គរ-យ៉ុងយូឆ្នាំ ២០០៦ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : [illegible]១៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **មួង សុវត្ថិ** ជាទីប្រឹក្សាក្រសួងពត៌មាន មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

__កន្លែងទទួល :__
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....១២១៥...អនក្រ.....-

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ០២គ្រឿង ជូនសប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានជួយសាងសង់អគារសិក្សា ចំនួន០១ខ្នង មាន០៦បន្ទប់ និងខ្លោងទ្វារ នៅសាលាបឋមសិក្សាពោធិរោង ក្នុងឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

-លោក **ថោង សុផាន** និង លោកស្រី **ផល លីម៉ុន** ថវិកា ចំនួន ២០.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **ឃន សុវណ្ណ** និង លោកស្រី **ថោង ចិន្តា** ថវិកា ចំនួន ៥.០០០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៧៤៦...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកំពង់ធំ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០៤គ្រឿង ជូនស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា និងសប្បុរសជន ជប៉ុន ចំនួន ០៣រូប ដែលបានបរិច្ចាគថវិកា សរុបទាំងអស់ចំនួន ១០១.២១៣ ដុល្លារអាមេរិក ដើម្បីជួយកសាងអគារសិក្សា ចំនួន០៤ខ្នង ស្មើ ២០បន្ទប់ សំភារៈសិក្សា មាន តុ-កៅអី ក្តារខៀន បង្គន់អនាម័យ ចំនួន ០៤បន្ទប់ និងអណ្តូងទឹកស្អាត ចំនួន០២ ស្ថិតនៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម :-

១-ស្ថានទូត ជប៉ុនប្រចាំកម្ពុជា (KUSANONE)
២-លោក **តាកេស៊ី យូកាវ៉ា** (TAKESHI YUKAWA)
៣-លោកស្រី **ជុនកូ អូហារ៉ា** (JUNKO OHARA)
៤- SAKAI RYOTO International Lions Club

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៤០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ *សេនា* ជូន **Mr. Edmund Tan Choon Hui** លេខាទី១ និងជាតំណាងផ្នែកយោធាអមស្ថានទូត សឹង្ហបុរី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងការលើកស្ទួយទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ កម្ពុជា-សឹង្ហបុរី ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦
**នាយករដ្ឋមន្ត្រី**
**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧២៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនចំពោះលោក **Colonel Andrie Tardiwan Utama Soetarno , S.E. MDS** អនុព័ន្ធយោធាឥណ្ឌូនេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អ ក្នុងការលើកស្ទួយ ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ កម្ពុជា-ឥណ្ឌូនេស៊ី ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៦
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩ អនក្រ.

## សេចក្តីសំរេច

ស្តីពី

ការទទួលដីប្រមាណ ២០ហិកតា នៅភូមិស្រះកែវ ស្រុកសង្កែ ខេត្តបាត់ដំបង សំរាប់ធ្វើជាកន្លែងពិសោធន៍កសិកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៣១ សសរ. ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល
- ផ្អែកតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១.-** ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ចាន់ ណារ៉េត** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងជាអនុប្រធានគណៈកម្មការ ដូចមានចែងក្នុងសេចក្តីសំរេចលេខ ៣១ សសរ. ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល ឱ្យទទួលដីប្រមាណ ២០ហិកតា នៅភូមិស្រះកែវ ស្រុកសង្កែ ខេត្តបាត់ដំបង ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ជូនសាកលវិទ្យាល័យបាត់ដំបង សំរាប់ធ្វើជាកន្លែងពិសោធន៍ ។

**ប្រការ ២.-** ឯកឧត្តម **ចាន់ ណារ៉េត** មានភារកិច្ចដូចខាងក្រោម :

- ចាត់ចែង ការថែរក្សា និងគ្រប់គ្រងដីឱ្យបានល្អប្រសើរ
- ចាត់ចែងការកសាងហេដ្ឋារចនាសម្ព័ន្ធនានានៅលើទីតាំងដីនោះ សំរាប់បំរើឱ្យការងារពិសោធន៍របស់និស្សិតសាកលវិទ្យាល័យបាត់ដំបង ដោយធ្វើការអំពាវនាវរកជំនួយឧបត្ថម្ភពីសប្បុរសជននានា

- រាយការណ៍ និងបំពេញការងារមួយចំនួនទៀតតាមការប្រគល់ភារកិច្ចពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ។

**ប្រការ ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តបាត់ដំបង និងឯកឧត្តម **ចាន់ ណារ៉េត** ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**ជ.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

**<u>កន្លែងទទួល</u> :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ដូចចែងក្នុងប្រការ ៣
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**......០៤......បប

# បទបញ្ជា
# ស្តីពី
# ការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

អនុលោមតាម ជំពូក ៧ ចែងអំពីគោលការណ៍ទូទៅនៃការអនុវត្តន៍ថវិកា នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំជាបន្តបន្ទាប់ ព្រមទាំងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស សំរាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលជាសមាសភាគមួយដ៏សំខាន់នៅក្នុងចំណូលថវិកាចរន្ត រាជរដ្ឋាភិបាលដាក់ចេញនូវបទបញ្ជាមួយចំនួនដូចខាងក្រោម ៖

## ***អំពី អាណាប័ក និង គណនេយ្យករសាធារណៈ***

**១-**អាណាប័កដើមខ្សែដែលបញ្ជាប្រតិបត្តិចំណូល និង បញ្ជាចំណាយនៃថវិការដ្ឋ រួមមាន រដ្ឋមន្ត្រី ប្រធានស្ថាប័នសាធារណៈនានា ។ អាណាប័កដើមខ្សែ ត្រូវធ្វើប្រតិភូកម្មអំណាចជូនអភិបាលខេត្ត-ក្រុង ធ្វើជាអាណាប័កផ្ទេរសិទ្ធិចំពោះកិច្ចប្រតិបត្តិការថវិការដ្ឋក្នុងដែនដី ខេត្ត-ក្រុងរបស់ខ្លួន ។

ចំពោះកិច្ចប្រតិបត្តិការថវិកាសាលាខេត្ត-ក្រុង អភិបាល ខេត្ត-ក្រុងជាអាណាប័កដើមខ្សែ ។ រីឯ ថវិកាឃុំ-សង្កាត់ មេឃុំ-ចៅសង្កាត់ជាអាណាប័កដើមខ្សែនៃកិច្ចប្រតិបត្តិការថវិការបស់ខ្លួន ។

ប្រភេទគណនេយ្យករសាធារណៈរបស់រដ្ឋ រួមមាន ៖

- គណនេយ្យករផ្ទាល់របស់ រតនាគារ
- គណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ

អាណាប័ក និង គណនេយ្យករ មានមុខងារវិសមិតពីគ្នា ។

## ទិធានស្តីពីការប្រមូលចំណូលមិនមែនសារពើពន្ធតាមរយៈកិច្ចសន្យា

**២**-កិច្ចសន្យាដែលបានព្រមព្រៀងរវាងភាគីសងខាងរួចហើយមាន :

**ក/** កិច្ចសន្យាស្តីពីការជួល-លក់ទ្រព្យសម្បត្តិរដ្ឋ

**ខ/** កិច្ចសន្យាស្តីពីការបង្កើតក្រុមហ៊ុនចំរុះ

**គ/** កិច្ចសន្យាស្តីពីសម្បទាន

**ឃ/**កិច្ចសន្យាស្តីពីការផ្គត់ផ្គង់សេវាសាធារណៈនិងកិច្ចសន្យាផ្សេងៗ

-ចំពោះកិច្ចសន្យាក្នុងប្រភេទ (ក) អាណាប័កគ្រប់ក្រសួង-ស្ថាប័ន , សាលាខេត្ត-ក្រុង ត្រូវពិនិត្យប្រភេទចំណូលមិនមែនសារពើពន្ធ ដែលបានកំណត់រួចហើយ និងត្រូវរៀបចំបោះផ្សាយដីកាចំណូលអោយបានត្រឹមត្រូវស្របតាមកិច្ចសន្យា រួចហើយត្រូវផ្ញើដីកាចំណូលទាំងនោះ ដោយអមជាមួយនូវកិច្ចសន្យាដែលពាក់ព័ន្ធមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (រតនាគារជាតិ) កុំបីខាន ។

-ចំពោះកិច្ចសន្យាប្រភេទ (ខ) អាណាប័កគ្រប់ក្រសួង-ស្ថាប័ន, សាលាខេត្ត-ក្រុង និងមន្ទីរជំនាញខេត្ត-ក្រុងត្រូវធ្វើការកំណត់ទឹកប្រាក់ចំណូលប្រចាំឆ្នាំដែលត្រូវបែងចែក រួចហើយត្រូវរៀបចំបោះផ្សាយដីកាចំណូលអោយបានត្រឹមត្រូវ និងត្រូវផ្ញើដីកាចំណូលទាំងនោះ ដោយអមជាមួយកិច្ចសន្យាដែលពាក់ព័ន្ធមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (រតនាគារជាតិ) មិនអោយហួសពីថ្ងៃទី២០ ខែមេសា នៃឆ្នាំបន្ទាប់ឡើយ ។

-ចំពោះកិច្ចសន្យាប្រភេទ (គ) និង (ឃ) ដែលបានកំណត់អោយបង់ចំណែកនៃប្រាក់ចំណូល ( Revenue - Sharing ) ប្រចាំខែ អាណាប័ក គ្រប់ក្រសួង-ស្ថាប័ន , សាលាខេត្ត-ក្រុង និងមន្ទីរជំនាញខេត្ត-ក្រុងត្រូវ ធ្វើការកំណត់ទឹកប្រាក់ចំណូលប្រចាំខែ ដែលត្រូវបែងចែក រួចហើយត្រូវរៀបចំបោះផ្សាយដីកាចំណូលអោយបានត្រឹមត្រូវ និងត្រូវផ្ញើដីកាចំណូលទាំងនោះ ដោយអមជាមួយកិច្ចសន្យា ដែលពាក់ព័ន្ធមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( រតនាគារជាតិ ) មិនអោយហួសពីថ្ងៃទី ១៥ នៃខែបន្ទាប់ឡើយ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( រតនាគារជាតិ ) នឹងត្រូវផ្តល់ព័ត៌មានទៅវិញអំពីបេឡានិច័យនៃចំណូលដែលបានបង់ផ្ទាល់ចូលនៅបេឡា ឬ ដោយការបង្វែរចូលគណនីរតនាគារ នៅធនាគារជាតិនៃកម្ពុជាជូនក្រសួង-ស្ថាប័ន , សាលាខេត្ត-ក្រុង និងមន្ទីរជំនាញខេត្ត-ក្រុងដែលពាក់ព័ន្ធ ដើម្បីធ្វើការចុះបញ្ជីគណនេយ្យ ។

**៣**-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការត្រួតពិនិត្យ និងតាមដានជាប្រចាំនូវការប្រមូលចំណូលមិនមែន-សារពើពន្ធ ដោយផ្អែកទៅលើកិច្ចសន្យាដែលក្រសួង-ស្ថាប័ន សាលាខេត្ត-ក្រុងបានចុះហត្ថលេខាជាមួយរូបវន្ត បុគ្គលនីតិបុគ្គលឯកជន ឬ នីតិបុគ្គលសាធារណៈ ។ គ្រប់ក្រសួង-ស្ថាប័ន សាលាខេត្ត-ក្រុង និងមន្ទីរជំនាញ ត្រូវមានកាតព្វកិច្ចធ្វើការងារជាមួយមន្ត្រីជំនាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានចាត់បញ្ជូនឱ្យមកធ្វើការត្រួតពិនិត្យ និងតាមដានចំណូលទាំងនេះ ។ បុគ្គលដែលមានទំនាក់ទំនងដល់ការកាន់កាប់បញ្ជីគណនេយ្យ ត្រូវផ្តល់ឯកសារត្រួតពិនិត្យ

ឱ្យបានទៀងទាត់ និងទាន់ពេលវេលា មិនត្រូវបង្វែបង្វង់ ឬ ពន្យាពេលដោយយកលេស ឬ មូលហេតុណាមួយដើម្បីធ្វើឱ្យរាំងស្ទះក្នុងការត្រួតពិនិត្យឡើយ ។

**៤**-ប្រភេទចំណូលមិនមែនសារពើពន្ធ ដែលបានកំណត់រួចហើយតាមរយៈការចុះកិច្ចសន្យា ដូចជាការលក់ ឬ ជួលទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សេវាកម្មផ្សេងៗ ឬ កិច្ចសន្យានានា ត្រូវខិតខំយកចិត្តទុកដាក់ជំរុញការបង់ចំណូលឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាដូចមានចែងក្នុងកិច្ចសន្យា ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន សាមី និងមន្ទីរជំនាញត្រូវសហការគ្នាអោយបានជិតស្និទ្ធក្នុងការជំរុញការបង់ចំណូលទាំងនេះ ។

**៥**-ដោយអនុលោមទៅតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ គ្រប់ក្រសួង-ស្ថាប័ន , សាលាខេត្ត-ក្រុង និងមន្ទីរជំនាញត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីធ្វើការកែប្រែកិច្ចសន្យាណា ដែលពិនិត្យឃើញថា មិនផ្តល់ផលប្រយោជន៍សមស្របដល់ភាគីរាជរដ្ឋាភិបាល ។ ត្រូវចាត់វិធានការលុបចោលនូវកិច្ចសន្យាណាដែលទាក់ទងនឹងការលក់ ឬ ជួលទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សេវាកម្មរបស់រដ្ឋ ឬ កិច្ចសន្យាដទៃទៀត ក្នុងករណីដែលស្ថាប័នមានសមត្ថកិច្ចបានធ្វើលិខិតក្រើនរំលឹកហើយ តែភាគីអ្នកទិញ ឬ អ្នកជួល ឬ អ្នកទទួលផលប្រយោជន៍នៅតែមិនគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាដែលធ្វើឱ្យប៉ះពាល់ដល់ចំណូលថវិការដ្ឋ ។

**៦**-រាល់កិច្ចសន្យាការលក់ ឬ ជួលទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សេវាកម្ម ឬ កិច្ចសន្យានានាដែលក្រសួង-ស្ថាប័នឬសាលាខេត្ត-ក្រុងបានចុះហត្ថលេខារួចហើយ ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ) ចំនួនមួយច្បាប់សំរាប់តំកល់ និង ដើម្បីតាមដានការអនុវត្តន៍កិច្ចសន្យាទាំងនោះ ។ រាល់ការកែប្រែកិច្ចសន្យា និងការចុះកិច្ចសន្យាស្តីពីការលក់ ឬ ជួលទ្រព្យសម្បត្តិរដ្ឋ ឬ ការផ្តល់សេវាកម្មផ្សេងៗ ឬ កិច្ចសន្យាផ្សេងទៀត ដែលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ មុននឹងចុះហត្ថលេខា ត្រូវតែមានការចូលរួមផ្តល់យោបល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនសិន ។

**៧**-ចំពោះកិច្ចសន្យាដែលតំរូវឱ្យបង់ជារបៀបម៉ៅការ ឬ ភាគរយលើចំណូលដុល (Revenue Sharing) ត្រូវជំរុញឱ្យក្រុមហ៊ុនដែលជាប់កិច្ចសន្យាទាំងនោះបង់ចំណូល ១ ( មួយ ) ខែម្តង ។ កាលបរិច្ឆេទនៃការបង់ចំណូលមិនឱ្យហួសពីថ្ងៃទី ២០ នៃខែបន្ទាប់ឡើយ ។ ចំពោះកិច្ចសន្យាណាដែលពុំបានចែងពីកាលបរិច្ឆេទនៃការបង់ចំណូល១ខែម្តងត្រូវធ្វើការកែសំរួលកិច្ចសន្យានេះឡើងវិញ ។

**៨**-ចំពោះកិច្ចសន្យាដែលតំរូវឱ្យបង់ភាគលាភ (Dividend) ត្រូវបង់មិនឱ្យហួសថ្ងៃទី ៣០ ខែ មេសា នៃឆ្នាំបន្ទាប់ ។ ក្រុមហ៊ុនត្រូវធ្វើសវនកម្ម ដោយសវនករដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានរួចរាល់មុនដំណាច់ខែមីនា នៃឆ្នាំបន្ទាប់ ។ ការបង់ភាគលាភនេះ ក៏ត្រូវអនុវត្តផងដែរ ចំពោះសហគ្រាសសាធារណៈ ។ កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាលស្តីពីការបែងចែកភាគលាភ ត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ) មួយសប្តាហ៍ក្រោយការប្រជុំ ។

**៩**-កិច្ចសន្យាទាំងអស់ត្រូវធ្វើជាភាសាខ្មែរ ។ ក្នុងករណីចាំបាច់ កិច្ចសន្យាខ្លះត្រូវសរសេរជាភាសាអង់គ្លេស ឬ បារាំង អមជាមួយភាសាខ្មែរ ។

## វិធានស្តីពីការប្រមូលចំណូល មិនមែនសារពើពន្ធ តាមរយៈ រជ្ជទេយ្យករចំណូល

**១០**-រជ្ជទេយ្យករចំណូលត្រូវកត់ត្រារាល់សកម្មភាពចំណូល និងការបង់ប្រាក់ចូលគណនីថវិការដ្ឋ នៅរតនាគារជាតិ ឬ ធនាគារជាតិនៃកម្ពុជា ចូលក្នុងសៀវភៅទិនានុប្បវត្តិជាប្រចាំ ។ ការកត់ត្រានេះ ត្រូវឆ្លុះបញ្ចាំងឱ្យឃើញនូវ

កាលបរិច្ឆេទ និងខ្លឹមសារនៃប្រតិបត្តិការឱ្យបានច្បាស់លាស់ និងងាយយល់ ។ នៅដំណាច់ខែនីមួយៗ រដ្ឋទេយ្យករចំណូល ត្រូវបញ្ចប់លេខនា ( កិច្ចចុះបញ្ជី) និងបង្កើតតារាងតុល្យភាព ។ នៅថ្ងៃទី ០១ នៃខែបន្ទាប់ត្រូវចាប់ផ្តើមកត់ត្រាសារជាថ្មី ដោយយោងសមតុល្យនៃស្ថានភាពចុងខែមុន ។

១១-រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរងនៃក្រសួង-ស្ថាប័ន សាលាខេត្ត-ក្រុង និងមន្ទីរជំនាញខេត្ត-ក្រុង ត្រូវទទួលខុសត្រូវដោយផ្ទាល់ ចំពោះប្រាក់កាស និងមូលនិធិទាំងឡាយដែលប្រមូលបាន និងរក្សាទុកដាក់លិខិតយុត្តិការ ព្រមទាំងកាន់កាប់បញ្ជីគណនេយ្យទ្វេភាគ ក្នុងករណីស្ថានភាពប្រតិបត្តិការជាក់ស្តែងតំរូវអោយកាន់កាប់តាមការចាំបាច់ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំ និងកិច្ចដំណើរការគណនីនៃរដ្ឋទេយ្យចំណូល ក្នុងក្របខ័ណ្ឌកំណែទំរង់គណនេយ្យសាធារណៈ ។

ចំពោះក្រសួង-ស្ថាប័ន សាលាខេត្ត-ក្រុង និងមន្ទីរជំនាញខេត្ត-ក្រុង ទាំងឡាយណាដែលកំពុងអនុវត្តចំណូល តែមិនទាន់បានបង្កើតរដ្ឋទេយ្យចំណូល និងតែងតាំងរដ្ឋទេយ្យករចំណូល រដ្ឋទេយ្យករចំណូលរងទេនោះ ត្រូវរូសរាន់រៀបចំបង្កើតរដ្ឋទេយ្យចំណូល និងតែងតាំងរដ្ឋទេយ្យករចំណូល , រដ្ឋទេយ្យករចំណូលរង ដោយប្រកាសអន្តរក្រសួង ឬដោយដីការបស់អភិបាលខេត្ត-ក្រុង ។ ហាមដាច់ខាតការប្រគល់ភារកិច្ចប្រមូល ឬ ទទួលចំណូល និងការទទួលខុសត្រូវប្រាក់កាសឱ្យទៅមន្ត្រីដែលពុំមែនជារដ្ឋទេយ្យករចំណូល ។

## វិធានស្តីពីការប្រមូលចំណូល និងការបង់ចំណូលចូលថវិការដ្ឋ

១២-គ្រប់ក្រសួង-ស្ថាប័ន សាលាខេត្ត-ក្រុង និងមន្ទីរជំនាញទាំងអស់ត្រូវខិតខំជំរុញឱ្យអស់លទ្ធភាពក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ ហើយត្រូវបង់ចូលរតនាគារជាតិឱ្យអស់ និងទាន់ពេលវេលា ដោយភ្ជាប់មកជាមួយនូវសាលាកប័ត្របង់ចំណូលចំនួន ៣ ( បី) ច្បាប់ និងមិនត្រូវរក្សាទុកចំណូលខ្លះ សំរាប់ចំណាយផ្សេងៗ ឡើយ ។

១៣-ហាមដាច់ខាតនូវការប្រមូលចំណូលដោយចំពោះ ឬ មិនចំពោះ ក្រៅពីចំណូលដែលបានអនុញ្ញាតដោយច្បាប់ ឬ បទបញ្ញត្តិដែលពាក់ព័ន្ធ ទោះបីជាចំណូលទាំងនោះស្ថិតក្នុងប្រភេទដូចម្តេចក៏ដោយ ។ អាជ្ញាធរដែលបានបញ្ជាឱ្យប្រមូលចំណូលទាំងនោះ និងមន្ត្រីដែលបានបង្កើតលិខិតស្នាម និងតារាងតំលៃពាក់ព័ន្ធ ព្រមទាំងភ្នាក់ងារប្រមូលចំណូលទាំងនេះ ត្រូវទទួលខុសត្រូវដោយផ្ទាល់នូវបទល្មើស ឬ កំហុសក្នុងការគ្រប់គ្រងចំពោះបទប្បញ្ញត្តិនានាដែលមាននៅក្នុងច្បាប់ជាធរមាន ។

## វិធានស្តីពីការគ្រប់គ្រងបំណុល :

១៤-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវដាក់ចេញវិធានការ ជាមួយក្រសួង-ស្ថាប័នសាមី និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការតឹងទារបំណុលដែលផ្នែកឯកជន ឬ ក្រុមហ៊ុននានាជំពាក់រដ្ឋ ដូចជា : បញ្ឈប់ការអនុញ្ញាតនាំចេញ-នាំចូល បង្កកគណនីធនាគារ បញ្ឈប់អាជ្ញាប័ណ្ណ និងមិនអនុញ្ញាតឱ្យចូលរួមលទ្ធកម្មសាធារណៈជាដើម ។ ករណីការអនុវត្តន៍តឹងទារបំណុលនេះមិនមានប្រសិទ្ធិភាព ក្រសួង-ស្ថាប័នសាមីត្រូវរៀបចំសំណុំរឿងប្តឹងទៅតុលាការ ។

១៥-ក្នុងករណីដែលកិច្ចសន្យាពាក់ព័ន្ធនឹងការលក់ ឬ ជួលទ្រព្យសម្បត្តិរដ្ឋ ឬ ក្នុងករណីដែលកិច្ចសន្យាពាក់ព័ន្ធទៅនឹងការបង់ថ្លៃសេវាកម្ម និងកិច្ចសន្យានានាពុំមានចែងអំពីការផាកពិន័យទេនោះ ត្រូវអនុវត្ត ពិន័យ ២% ក្នុង១ខែ លើចំនួនទឹកប្រាក់ដែលពុំទាន់បានទូទាត់ជូនរដ្ឋចាប់ពី ៦០ (ហុកសិប) ថ្ងៃ ក្រោយកាលកំណត់ ។ ប្រាក់ពិន័យ នឹងត្រូវចាត់

ទុកជាបំណុល ដែលត្រូវគិតការប្រាក់បន្ថែមក្នុងករណីដែលមិនបានបង់ប្រចាំខែ (ការប្រាក់សមាស) ។ ទោះយ៉ាងនេះក្តី បំណុលនេះក៏មិនអាចរក្សាទុកឱ្យហួសពីរយៈពេល៦ (ប្រាំមួយ) ខែឡើយ ដោយត្រូវដាក់បញ្ចូលទៅក្នុងវិធានការតឹងទារបំណុលដែលត្រូវកំណត់អំពីការបង់ពិន័យបន្ថែម ឬ ឈានដល់ការលុបកិច្ចសន្យា ។

## វិធានស្តីពីការលើកទឹកចិត្ត ការពិន័យ និងទណ្ឌកម្ម

**១៦**-ការជូនរង្វាន់ដល់ក្រសួង-ស្ថាប័ន សាលាខេត្ត-ក្រុង និងមន្ទីរជំនាញ ឬ មន្ត្រីដែលមានស្នាដៃ ក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួង-ស្ថាប័ន រដ្ឋបាលកណ្តាល ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមការយល់ព្រមពីរាជរដ្ឋាភិបាល ។

